# ការសំភាសន៍របស់លោកពូ  ឌិន ជឿន

កៈ អ្នកដែលសំភាសន៍ឈ្មោះ ញៀម សុគន្ធា          ខៈ អ្នកដែលត្រូវគេសំភាសន៍ ឌិន ជឿន

## ការសង្ខេបរបស់លោកពូ  ឌិន ជឿន

លោកពូឌិន ជឿនជាអ្នកកើតនៅភូមិជីមូរ ហើយគាត់ជាកូនអ្នកឡើងត្នោត ហើយឪពុកលោកពូស្លាប់ព្រោះតែឡើងត្នោតហើយធ្លាក់គឺធ្លាក់ច្រើនដងតែមិនមែនធ្លាក់ស្លាប់ភ្លាមនោះទេគឺដោយសារក្រំហើយឈឺរហូតដល់ថ្នាក់ស្លាប់ ។លោកពូមានបងប្អូន៩នាក់ហើយឥឡូវស្លាប់អស់៤នាក់នៅ៥លោកពូជាកូនបន្ទាប់ពៅ។ លោកយាយគាត់ជាអ្នកធ្វើនំអាកោរហើយម្ដាយគាត់នៅរស់សព្វថ្ងៃ ហើយធ្វើអំបោសលក់ហើយនឹងកន្ត្រក។ លោកពូគាត់អត់ចេះអក្សរទទេព្រោះគាត់ឈឺអត់បានរៀន។

កៈ ជាដំបូងនាងខ្ញុំសូមថ្លែងអំណរគុណដល់លោកពូដែលបានអោយញ៉ុមសំភាសន៍អំពីជីវប្រវត្តិរបស់លោកពូនាងខ្ញុំឈ្មោះញៀម សុគន្ធា ជាអ្នកសំភាសន៍អំពីជីវប្រវត្តិរបស់លោកពូនៅក្នុងថ្ងៃនេះ ពួកយើងសំភាសន៍គឺនៅក្នុងថ្ងៃទី២៥ខែមិនា ឆ្នាំ២០១៨ ការសំភាសន៍នេះគឺមានទីតាំងស្ថិតនៅក្នុងភូមិព្រៃកហូរខាងលិច សង្កាត់ព្រៃកហូរ ក្រុងតាខ្មៅ ខេត្តកណ្ដាល ប្រទេសកម្ពុជា។អ៊ីចឹងនាងខ្ញុំសូមចាប់ផ្ដើមសួរអំពីជីវប្រវត្តិរបស់លោកពូតែម្ដង អ៊ីចឹងលោកពូសូមប្រាប់ឈ្មោះពេញហាំ លោកពូឈ្មោះអីគេវិញ?

ខៈ ញ៉ុមឈ្មោះជឿន។

កៈ អីគេជឿន?

ខៈ ឌិន ជឿន។

កៈ ឌិន ជឿន?

ខ៖បាទ!!

ក៖ចាំ!!លោកពូសព្វថ្ងៃមានអាយុប៉ុន្មានឆ្នាំហើយ?

ខ៖ ញ៉ុម៥៤។

ក៖ តែ៥៤ទេហោ?

ខ៖បាទ!!

ក៖ចូលឆ្នាំថ្មី៥៥ហើអី?

ខ៖បាទ!!

ក៖តែជិតចូលឆ្នាំហើយនឹង?

ខ៖ ជិតចូលឆ្នាំហើយ។

ក៖ លោកពូកើតឆ្នាំខ្មែរកើតឆ្នាំអីគេវិញ?

ខ៖ ញ៉ុមកើតឆ្នាំរោង។

ក៖ឆ្នាំរោងហោ?

ខ៖បាទ!!

ក៖លោកពូចាំថាខ្លួនឯងកើតខែខ្មែរកើតខែអីគេអីអត់?

ខ៖ អត់ចាំទេ។

ក៖ដូចកក្តិក ភទ្របទ អីវ៉ាន់ហ្នុំ?

ខ៖ អត់ អត់ចាំ។

ក៖អត់ចាំទេហោ?

ខ៖បាទ!!

កៈ អត់អីទេ!!ពូចាំឆ្នាំខ្លួនឯងកើតទេ ពូកើត១៩០០ប៉ុន្មានដែរ?

ខៈ ញ៉ុមកើតជំនាន់ប៉ុល ពត ញ៉ុមប៉ុននេះ និយាយរួមប៉ុណ្ណឹង!!ដើរលើកអាចមន៍គោ។

កៈ ៣ឆ្នាំហ្នឹង?

ខៈបាទ?

កៈអាអូន៣ឆ្នាំតើ!!

ខៈ ហ្នឹង ប៉ុណ្ណឹងញ៉ុមដើររើសអាចមន៍គោញ៉ុមដើរកាត់ផាងខេត។

កៈ ប៉ុណ្ណឹងហោ?

ខៈ បាទប៉ុណ្ណឹងញ៉ុមដើរកាត់ផាងខេត លើកអាចមន៍គោ។

កៈចាំ!!

ខៈមានតែប៉ុណ្ណឹង។

មិត្តភក្តិៈ កើតឆ្នាំ៧០(១៩៧០)ទេទំនង!!

ខៈ បាទ!!

កៈតែពូកើតទាន់លន់ នល់តើហី?

ខៈ ហ៊ីទាន់ ទាន់ ព្រោះយើងប៉ុណ្ណឹងហើយពេលជំនាន់អាពត។

កៈហ្ហ៎ហ្នឹងហើយៗ។

ខៈ ព្រោះអីញ៉ុមដឹងគេអាករជាងត្នោតអារករជាងអីញ៉ុមដឹងទាំងអស់។

កៈចាំ!!

ខៈនៅយើង នៅខាងស្រុកនៅខេត្តតាកែវហាំ!!

កៈចាំ!!

ខ៖បាទ ព្រោះយើងគេជំលៀសទៅហ្នឹង!!

ក៖ហ៊ឹ!!

ខ៖ព្រោះគេឃើញ ឃើញគេវៃគល់ឬស្សីក៏ឃើញ ត្បូងចបក៏ឃើញ។

ក៖ ឃើញផ្ទាល់ភ្នែកហោ?

ខ៖បាទ!!ឃើញវៃត្បូងចបក៏ឃើញដែរ!!អារធាងត្នោតក៏យើងឃើញ។

ក៖ អញ្ចឹងពូអើរ តែដឹងតែឥឡូវអាយុ៥៥ឆ្នាំហើយ?

ខ៖ បាទ!!

ក៖ តែពូ ពូកើតខែប៉ុន្មានពូអត់ដឹងទេហោ?

ខ៖ អត់ អត់ដឹងអត់ចាំ។

ក៖អត់ចាំម៉ងហោ?

ខ៖បាទ!!

ក៖ពូអ្នកស្រុកភូមិណាវិញ កើតនៅភូមិឃុំណា ទីកន្លែងកំណើតហាំ??

ខ៖ ស្រុកភូមិជីម្ទូវ។

ក៖ មើលនិយាយស្រុកភូមិមើលភូមិឃុំអីគេខ្លះ?

ខ៖ ភូមិជីម្ទូវ ឃុំត្បែង។

ក៖ ឃុំត្បែង ភូមិជីម្ទូវ?

ខ៖បាទ!!

ក៖ស្រុកអីគេដែរពូ?

ខ៖ ស្រុកកណ្តាលស្ទឹងដែរ។

កៈស្រុកណ្ដាលស្ទឹងយើងហ្នឹងតើហី?

ខៈបាទ!!

កៈខេត្តកណ្ដាលហ្នឹង?

ខៈបាទ!!

កៈ និយាយទៅកើតមកនៅហ្នឹងម៉ងពូណោះ?

ខៈបាទ!!

កៈតែសព្វថ្ងៃពូរស់នៅឯណាវិញ?

ខៈ ញ៉ុមនៅព្រែកហូរលិចដែរ!!

កៈ ចាំផ្លាស់មកនៅព្រែកហូរយូរនៅពូ?

ខៈ ២ឆ្នាំ។

កៈតែ២ឆ្នាំទេហោ?

ខៈបាទ!!

កៈ អញ្ចឹងនៅហ្នឹងរហូតឬមួយក៏ផ្លាស់ប្ដូរផ្លាស់ប្ដូរ?

ខៈ អត់ទេ ញ៉ុមមានប្រពន្ធនៅហ្នឹងម៉ង។

កៈព្រែកហូរហ្នឹងហោ?

ខៈបាទ!!

កៈចាំ!លោកពូសំរាប់លោកពូមានបងប្អូនប្រុសស្រីប៉ុន្មាននាក់ដែរ?

ខៈ ញ៉ុមសំរាប់សព្វថ្ងៃហ្នឹងមានបងនៅ បងប្អូនប្រុស២នាក់ស្រីនៅ៣នាក់។

កៈចាំ!!

ខះបាទ!!

កះ អ្នកដែលនៅរស់៥នាក់?

ខះបាទ!នៅរស់។

កះ ចុះអ្នកដែលស្លាប់ទៅប៉ុន្មាន?

ខះ ស្លាប់ទៅ ទៅអស់៤។

កះ អញ្ចឹង៩នាក់?

ខះបាទ!

កះ អ៊ីចឹងពូជាកូនទីប៉ុន្មានវិញ?

ខះ ញ៉ុមពៅ
ថានិយាយរួមញ៉ុមពៅតែម្ដងទៅព្រោះអីស្លាប់ពៅបាត់ហើយ។កះហ្ហ៎!!ខះពៅដូចថាពៅម៉ងទៅ!!

កះ ស្លាប់ប៉ុន្មាននាក់អញ្ចឹង?

ខះ និយាយរួមស្លាប់ពៅអស់មួយបងញ៉ុមនោះអស់!!

កះ៣ហោ?

ខះបាទ!!

កះ ចា៎!!ត្រូវហើយ៩ដោយសារស្លាប់៤ តែឥឡូវលោកពូត្រូវបន្ទាប់ពៅមែនទេ?

ខះបាទ!!បើយើងបន្ទាប់ហើយនេះបន្ទាប់ហើយ!!

កះចា៎!!

ខះតែម្នាក់ឯង។

កះ អ៊ីចឹងលោកពូបងប្អូនរបស់ពូគាត់៩នាក់ទាំងអស់?

ខ៖ ៩នាក់។

ក៖ តែពេលគាត់ស្លាប់ហ្នឹងស្លាប់អាយុប៉ុន្មានខ្លះពួកគាត់ទាំង៩នាក់ហ្នឹង?

ខ៖ ស្លាប់ហ្នឹងមានកូនអស់ហើយហ្នឹង។

ក៖ ហ្ហ៎ចាស់ៗអស់ហើយ?

ខ៖ បាទបានស្លាប់ហ្នឹង ហើយស្លាប់មុនហ្នឹងខ្លះ ស្លាប់នឹងឥឡូវហ្នឹងខ្លះហា៎!!

ក៖ចា៎!!

ខ៖ស្លាប់ឥឡូវមានកូនមានចៅអីអស់ហើយ។

ក៖ហ្ហ៎!!

ខ៖គាត់ស្លាប់ហ្នឹង!!

ក៖ដោយសារជំងឺអីពូ?

ខ៖ ជំងឺ ជំងឺគាត់ បាទ!!

ក៖ ពូឈ្មោះទាំងអស់បងប្អូនទាំង៩នាក់ពូចាំទាំងអស់ទេ ?មើលឈ្មោះអីគេខ្លះបងប្អូន?

ខ៖ ឈ្មោះបងប្អូនទាំងអស់ បងបង្អស់ឈ្មោះ ហា៎បងបង្អស់ឈ្មោះម៉ៃ។

ក៖ចា៎!!

ខ៖ដល់ហើយឈ្មោះជា ឈ្មោះវិត ឈ្មោះមីលី។

ក៖ ៤នាក់ហើយនៅ៥នាក់ទៀត!!

ខ៖ បាទ ហើយដល់នៅពល់ថ្ងៃហ្នឹងឈ្មោះ បងណុប បងម៉ូ បងមើរ បងចុល ញ៉ុមហ្នឹងម៉ង!!

ក៖ ចា៎អ៊ីចឹង៩ហើយណោះ គ្រកូលឱនទាំងអស់ពូណោះ?

ខ៖ បាទ!!

កៈ ចាំ!!ពូពីក្មេងមកលេងអីគេខ្លះជាមួយបងប្អូនដែរ?

ខៈលេង?

កៈ ដូចរបៀបថាចូលចិត្តលេងអីគេហាំ?

ខៈ លេង!! អត់មានអីលេង។

កៈ មើលពេលមុនមកចាំអីគេខ្លះជាមួយបងប្អូនខ្លះ?

ខៈ មានអីគ្រាន់តែទៅឃ្វាលគោលេងហឹងលេងអីហ្នឹងណាស់!!

កៈ លេងហឹងហោ?

ខៈបាទ!!

កៈ ពូអាលេងហឹងហ្នឹង គេលេងម៉េចទៅញ៉ុមភ្លេចបាត់ហើយនេះហិ!!

ខៈ លេងហឹងយើងជីករណ្ដៅមួយទៅហើយយើងកូនប៉ុណ្ណឹងទៅ !!

កៈចាំ!!

ខៈហើយហឹង!!!!!!!!!!

កៈ និយាយ!!

ខៈ អ៊ូៗៗៗៗៗៗៗៗៗៗៗៗៗៗអីចឹងទៅណាស់!!

កៈឥឡូវអត់សូវឃើញមានក្មេងៗលេងទេពូហោ?

ខៈ ឥឡូវវាអត់លេងទេឥឡូវស្រុកឥឡូវ។

កៈចាំ!!

ខៈបាទ!!

កៈមានតែពេលមុនអីវ៉ាន់អញ្ចឹងទៅណាស់។

ខ៖បាទ ពេលមុនលេង ។

ក៖ តែដល់ពេលឥឡូវដូចអាល្បែងមុនៗឥឡូវលែងមានអីអស់ហើយពូណោះ?

ខ៖ បាទដូចថាលេងឈូងលេងអីហ្នឹងបាត់អស់ហើយ។

ក៖ ចាំ!!ពេលមុនវិញហាំ តែពេលខែជិតដល់ខែចូលឆ្នាំអីហ្នឹង លេងឈូង!!

ខ៖ លេងអង្គុញ លេងអី ។

ក៖ តែឥលូវបាត់អស់រលីង។

ខ៖បាត់អស់ ប្រជាប្រិយអីបាត់អស់ហើយ។

ក៖ ពូបងប្អូនពូទៅរៀនអីអត់?

ខ៖បងប្អូនញ៉ុមបានរៀនដែរ រៀន
បងញ៉ុមនៅសព្វថ្ងៃបានទៅរៀនដែរគ្រាន់តែដល់ពេលគាត់មានប្រពន្ធហ្នឹងដល់គាត់ខូចចិត្តគាត់ ទ្រង់ឡេឡឺឡេឡឺម៉េចទេ!!

ក៖ ទៅមានប្រពន្ធខូចចិត្តវិញថី?

ខ៖ ដឹងម៉េចទេ ដូចថាត្រូវរបស់គេតិចអីតិចអីចឹងទៅណាស់។

ក៖ ត្រូវអំពើរបស់ប្រពន្ធ?

ខ៖មិនមែនទេ មុនដំបូងគាត់ធ្វើនៅភ្នំពេញ ធ្វើការនៅភ្នំពេញហាំ!!

ក៖ចាំ!!

ខ៖ហើយស្រីគេស្រលាញ់ ទាល់តែមកវិញដូចថាគាត់វិល វិលខួរក្បាលគាត់
បងប្រុសញ៉ុមនៅខេត្តតាកែវហ្នំ!!ដល់តែមកវិញគាត់រៀងវិលដូចគាត់ម៉េចទេ!!ដូចថាខួរក្បាលដូចថាអត់មានចងចាំហាំ!!ក៖ចាំ!!ខ៖ដូចថាគាត់វិល ខួរក្បាលគាត់អស់។

ក៖ដូចប្រហែលជាត្រូវអំពើគេអញ្ចឹងទៅពូណោះ?

ខះបាទ!!

កះធម្មតាភាគច្រើនខ្មែរយើងភាគច្រើនធ្វើអំពើ។

កះ គេទៅហ្នឹងគេទៅគេស្រលាញ់ទាល់តែនេះអ៊ីចឹងទៅយើងអត់ស្រលាញ់គេ!!

កះហ្ន៎!!

ខះហើយដល់យើងមកមក
មកស្រុកវិញហាំ!!ហើយណោះបែបគេធ្វើមិនដឹងអីមិនដឹងទេ!!ញ៉ុមអត់នេះដែរ ព្រោះអី
ឥឡូវមើលដែរហ្នឹង។

កះតែគាត់ឥឡូវគាត់ស្លាប់ឬក៏គាត់នៅរស់?

ខះ នៅតើ។

កះនៅរស់ទេហេ?

ខះបាទ!!

កះអញ្ចឹងទឹមតែឥឡូវៗហ្នឹងទេកើតឡើងអញ្ចឹងពូ?

ខះ យើង៣ ៤ឆ្នាំមុនហ្នឹង។

កះ ហ្ន៎អ៊ីចឹងទល់ឥឡូវហ្នឹង នៅតែរាងអញ្ចឹង?

ខះបាទ!!

កះហើយមានយកទៅពេទ្យទៅអីទេអញ្ចឹង?

ខះយកទៅតើ។

កះហ្ន៎តែនៅតែអត់ជាហី?

ខះ បាទ!!យកទៅពេទ្យយកទៅគ្រូខ្មែរយកទៅអីអញ្ចឹងទៅ!!

កះតែនៅតែអត់កើត?

ខ៖បាទ!!

ក៖ អញ្ចឹងមានតែតាមហ្នឹងហើយមិនដឹងធ្វើម៉េច!!

ខ៖បាទតាមដំនើរហើយ។

ក៖ ពូបងប្អូនទាំងអស់អ្នកដែលជិតស្និតជាងគេបងប្អូនទីប៉ុន្មានដែរ?

ខ៖ ញុំមនៅសព្វថ្ងៃបងប្អូនដែលជិតស្និតមានតែបង២នាក់ទេ។

ក៖ អ្នកណាគេ មួយណាវិញ?

ខ៖ ឈ្មោះបងម៉ើរ ហើយបងចុល។

ក៖ម៉េចដែរហើយម៉េចបានជិតស្និតគ្នាអញ្ចឹង?ទំនាក់ទំនងម៉េចដែរទៅ?

ខ៖ ថាដូចថាយើងឈឺអញ្ចឹងទៅមើលយើងឈឺយប់ព្រលប់អីអ៊ីចឹងទៅណាស់
បានពីរនាក់ហ្នឹងហើយនឹងក្មួយ។

ក៖ចាំ!!

ខ៖បាទក្មួយបានមើលថៃទាំអញ្ចឹងដែរ ពេលញុំមទៅ
ញុំមទៅស្រុកអញ្ចឹងពេលញុំមឈឺគាត់មើលញុំមអញ្ចឹងទៅ!!

ក៖ហ៊ឺៗ!!

ខ៖ហើយនឹងម្តាយហ្នឹង!!

ក៖ចាំអញ្ចឹងលោកពូសំរាប់ម្តាយលោកពូគាត់ឈ្មោះអីគេដែរ?

ខ៖ ឈ្មោះជុំ មឿន។

ក៖ ជុំ មឿន?

ខ៖បាទ!!

ក៖គាត់ស្លាប់ឬក៏រស់លោកពូ?

ខ៖នៅ!!

ក៖នៅរស់ទាល់តែសព្វថ្ងៃពូហោ?

ខ៖ បាទ!!ឥឡូវនៅតែម្ដាយទេ។

ក៖ ចាំម្ដាយលោកពូអាយុគាត់សព្វថ្ងៃអាយុគាត់ប៉ុន្មានហើយនឹង?

ខ៖ ហោ៧០ជាងហើយ។

ក៖ ៧០ប៉ុន្មានវិញ?

ខ៖ ៧៦។

ក៖៧៦?

ខ៖បាទ!!

ក៖អូយចាំច្បាស់ណាស់ !!ឆ្នាំខ្មែរគាត់កើតសត្វអីគេវិញពូ?

ខ៖ដូចគ្នាដូចញ៉ុមដែរ ឆ្នាំរោងដែរ។

ក៖ ឆ្នាំរោងដែរ?ខ៖បាទ!!ក៖តែពូអត់ចាំថ្ងៃខែឆ្នាំកំណើតរបស់គាត់ទេហោ?

ខ៖ អត់ទេ។

ក៖ គាត់អ្នកស្រុកមកពីណាវិញ?

ខ៖ ស្រុកហ្នឹងហើយ ស្រុកហ្នឹងម៉ង!!

ក៖ មើលពូគេហៅអីគេដែរ និយាយអោយច្បាស់ម្ដងទៀតមើល?

ខ៖ ភូមិជីមូរ ឃុំត្បែង ស្រុកកណ្ដាលស្ទឹង ។

ក៖ខេត្តកណ្ដាល!!

ខ៖បាទ!!

កៈនៅម្តុំណាវិញពូ?

ខៈ នៅជិតត្រាំខ្នារអាដើមរកា។

កៈហ្ហ៎!!

ខៈខាងជើងដើមរកា។បាទ!!

កៈជិតៗនេះទេអញ្ចឹងហោ??

ខៈបាទ !!ផ្លូវយើងមកទន្លេបាទីហ្នឹង។

កៈ ហ្នឹងហើយ។

ខៈតែគ្រាន់តែញ៉ុមនៅជាប់ផ្លូវជាតិលេខ៣។

កៈចា៎!!

ខៈបាទ!!

កៈនៅខាងណោះជិតខាងត្រាំខ្នារណោះវិញ!!

ខៈ នៅខាងត្បូងដើមរកា។

កៈដើមរកា!!

ខៈហាខាងជើងដើមរកា បាទ!!

កៈ ចា៎អ្នកស្រុកមកពីហ្នឹង?

ខៈបាទៗ!!

កៈពូម្តាយរបស់លោកពូគាត់ជាមនុស្សដែរមានចរិកម៉េចដែរ?មើលនិយាយពូនឹងប្រវត្តិម្តាយពូស្រលាញ់គាត់ម៉េចដែរពូ?

ខៈ អានិតគាត់អញ្ចឹងទៅ ពេលទៅអោយលុយអោយកាក់អីគាត់អញ្ចឹតងទៅ អោយខែ!!

កៈ ញ៉ុមស្មានតែគាត់អោយពូវិញ!!ម៉េចទៅពូ?

ខៈ ជីវភាពដូចថាខ្វះខាតអិចឹងទៅ ញ៉ុមឧស្សាហ៍ទៅមើលគាត់ដែរហ្នឹង សព្វថ្ងៃហ្នឹង។

កៈចាំ!!

ខៈមួយអាទិត្យអីទៅ ពីរអាទិត្យអីទៅ។

កៈហ៊ឺៗ!!

ខៈមើលគាត់អីទៅ ។

កៈចាំ!!

ខៈចុះគាត់មានពឹងណាមានតែពឹងកូន។

កៈហ៊ឺៗ!!

ខៈហើយយើងចេះតែទៅមើលគាត់ទៅ។

កៈចាំ!!

ខៈបានលុយកាក់អីតិចតួចទៅទៅទៅមើលទៅ!!

កៈហ៊ឺៗ!! ពីដើមមកម្ដាយពូគាត់ប្រកបមុខរបរអីគេដែរលោកពូ?

ខៈ ពីដើមមកគាត់ធ្វើកន្ត្រក។

កៈម្ដាយបហា?

ខៈ បាទ!!ទាល់តែឥឡូវគាត់ធ្វើអំបោសហើយកន្ត្រកដែរ ធ្វើកន្ត្រកយើងល្មមៗហ្នឹង!!

កៈកន្ត្រកអីពូ ញ៉ុមចង់ដឹង?

ខៈ អាកន្ត្រកយើងអាកន្ត្រកខ្សែជ័រហ្នឹង!!

កៈខ្សែជ័រ?

ខ៖បាទ!!

ក៖អាកន្ត្រកយើងយួរទៅផ្សារហ្នឹងមែន?

ខ៖បាទ!!

ក៖ហើយខ្សែជ័រហ្នឹងយកមកពីណាវិញបានវិញកើត?

ខ៖បងញ៉ុមគាត់យកមកពីរោងចក្រមក។

ក៖ហ្ហ៎!!ពូចេះពីរបៀបធ្វើកន្ត្រកហ្នឹងទេ?

ខ៖ញ៉ុមអត់ទេ ប៉ុន្តែម្ដាយចេះ។

ក៖ ចាំ!!ពូអើរតាមឃើញគាត់មករបៀបដែលគាត់ធ្វើកន្ត្រកហ្នឹងរបៀបដែលគាត់ចាក់ហ្នឹង
វាម៉េចទៅ?

ខ៖ ត្បាញ យើងត្បាញវែង។

ក៖ នៅនឹងដៃអីចឹងទៅហោ?

ខ៖បាទនៅហ្នឹងដៃ។

ក៖មិនមែនកន្ត្រកអីចេញពីដើមឈើអីទេហី?

ខ៖ អត់ទេ អាខ្សែជ័រយើងត្បាញធ្វើជាកន្ត្រកហ្នឹង!!

ក៖ចាំ!!ហ្នឹងហើយ។

ខ៖ហើយគាត់ធ្វើអំបោសជក់ត្នោតហ្នឹង។

ក៖ហ្ហ៎!!

ខ៖បាទ!!

ក៖ ពូចេះអាធ្វើអំបោសពីដើមត្នោតហ្នឹង ទេអាអំបោសហ្នឹងចេះធ្វើមួយហ្នឹងអត់?

ខ៖ ញ៉ុមអត់ទេ។

ក៖ អត់ដែរ?

ខ៖បាទ!!

ក៖តែយាយទេហី?

ខ៖ បាទតែម៉ែទេ!!

ក៖ អាហ្នឹងដូចគេឃើញដំអោយទូកៗមែនពូ?

ខ៖ បាទ ដំអោយទូកៗហើយពេលហ្នឹងយើងហែកវាអោយសុះៗទៅយើងយកចងទៅ!!

ក៖ចាំ!!

ខ៖បាទ!!

ក៖ហើយដល់ពេលអញ្ចឹងបានវិញបានអីមកអញ្ចឹងទៅពូណោះ?

ខ៖បាទ!!យើងក្រងវាទៅបានធ្វើជាអំបោសហ្នឹង។

ក៖ តាមពិតមើលទៅក៏វាមិនពិបាកអីដែរ បើរៀនមួយភ្លេតទេពូណោះ?

ខ៖ អត់ពិបាកទេ  អត់ពិបាកទេ។

ក៖ ចាំ!!

ខ៖រឿងអំបោសអត់ពិបាកទេ ញ៉ុមអាចធ្វើបានយល់ តែដល់ពេលកន្ត្រកញ៉ុមអត់ចេះធ្វើទេ។

ក៖ចាំ លោកពូស្រលាញ់ម្តាយកន្លែងណាជាងគេវិញចំនុចកន្លែងណា?

ខ៖ ស្រលាញ់ពីចិត្តគាត់។

ក៖លើចិត្តម៉េចវិញទៅចិត្តគាត់ហាំ?

ខ៖គិតថារឿងចិត្តបានកូនខ្លាចយើងឈឺខ្លាចយើងដើរទៅណាទៅណីអីអិចឹងទៅយើងមានគ្រោះថ្នាក់អិចឹងអីអញ្ចឹងទៅ!!

កចាំ!!

ខ៖ភ័យបារម្ភអីចឹងទៅណាស់!!

ក៖ចាំ!!!

ខ៖បាទ!!

ក៖ ហើយគាត់ឧស្សាហ៍មកលេងណោះឬក៏គ្រាន់តែលោកពូទៅទេ?

ខ៖ គាត់អត់ដែលមកនេះទេ គាត់ចេះតែឧស្សាហ៍ឈឺ ។

ក៖ហ្ហ៎!!

ខ៖បាទ!!

ក៖ ជំងឺចាស់ជរាឬក៏មានអីប្រចាំកាយដែរលោកពូ?

ខ៖ គាត់ឈឺនិយាយរួមពិបាកថាដែរព្រោះគាត់មួយថ្ងៃកាត់មួយថ្ងៃកោរដែរ។

ក៖ហ៊ឺៗ!!

ខ៖ត្រូវអត់ឈឺអត់ទៅ គាត់ដើរធ្វើកន្រ្តកធ្វើអំបោសអិចឹងទៅ។

ក៖ចាំ!!

ខ៖បាទ!!

ក៖ ហើយគាត់យកអាកន្រ្តកអាអំបោសហ្នឹងគេមកយកដល់ផ្ទះ?

ខ៖ គេមកទិញដល់ផ្ទះម៉ង។

ក៖ហ្ហ៎អញ្ចឹងស្រួលណាស់អញ្ចឹងណោះ?

ខ៖ បាទ!!

ក៖គាត់អត់ដែលលក់ខ្លួនឯងទេណោះ?

ខ៖ គាត់អត់ដែលទៅលក់ខ្លួនឯងទេគឺគេមកទិញដល់ផ្ទះតែម្តង។

ក៖អញ្ចឹងស្រួលណាស់ពូ!!

ខ៖បាទ!!

ក៖ហេងហើយអ៊ីចឹង។ អ៊ីចឹងលោកពូចូលដល់ឪពុកវិញម្តង ឪពុកលោកពូគាត់ឈ្មោះអីគេវិញ?

ខ៖ ឪពុកញ៉ុមឈ្មោះឌិន !!! ភោគ ឌិន។

ក៖ ចាំ!ភោគ ឌិន?

ខ៖បាទ!!

ក៖ គាត់ស្លាប់ឬមួយក៏រស់?

ខ៖គាត់ស្លាប់ហើយ ជាង១០ឆ្នំា ១៥ឆ្នាំហើយ។

ក៖ ១៥ឆ្នាំហើយ?

ខ៖បាទ!!

ក៖ ពេលគាត់ស្លាប់អាយុប៉ុន្មានវិញ?

ខ៖ គាត់អាយុ៧០ជាង។

ក៖ ៧០ប៉ុន្មានគាត់ស្លាប់?

ខ៖ ៧៥។

ក៖ ៧៥គាត់ស្លាប់!!

ខ៖បាទ!!

កៈអ៊ីចឹងបងម៉ែច្រើនដែរហ្នឹងពូណោះ?

ខៈ បងច្រើន។

កៈ អ្នកស្រុកមកពីណាវិញឪពុកពូ?

ខៈ នៅស្រុកហ្នឹងដូចតែគ្នា។

កៈ អ្នកស្រុកនៅហ្នឹងដូចតែគ្នាដែរ?

ខៈបាទ!!

កៈនៅកណ្តាលស្ទឹង។

ខៈភូមិជិម្វរហ្នឹងជាមួយតែគ្នាហ្នឹង។

កៈ ចា៎!!ជីម្វរ!!

ខៈ ជីម្វរ បាទ!

កៈញ៉ុមអត់ស្វរដែលឮ ឮតែត្បែងៗហ្នូ៎!!ប៉ុន្តែអត់ដែលឮអាជីម្វរហ្នឹងសោះ!!

ខៈ ជីម្វរ ភូមិជីម្វរ។

កៈចា៎!!ឪពុកកើតឆ្នាំសត្វអីគេវិញពូ?

ខៈ អូយញ៉ុមអត់ស្គាល់ទេនេះ!!

កៈអត់ស្គាល់ទេហោ?

ខៈបាទ!!

កៈ អត់ស្គាល់អត់អីទេ!!គាត់កើតឆ្នាំណាពូចាំទេ?

ខៈ អត់ទេ។

កៈអត់ដែរហោ?

ខ៖បាទ!!

ក៖ចាំអត់អី គ្រាន់តែដឹងថាគាត់ស្លាប់១៥ឆ្នាំមុន២០០៧ពូហោ??

ខ៖ បាទ!!

ក៖ចាំហ្នឹងហើយ២០០៧ ២០០០អីហ្នឹងដកតាមហ្នឹងទៅដឹងហើយ!!ហ្នឹងហើយ!!

ខ៖បាទ!!

ក៖ហើយពេលហ្នឹងគាត់អាយុ៧៥ឆ្នាំហ្នឹងពេលគាត់ស្លាប់ហ្នឹង!!

ខ៖បាទ!!

ក៖លោកពូ ឪពុករបស់លោកពូគាត់គឺជាមនុស្សយ៉ាងម៉េចដែរ?ពូចាំទេ?

ខ៖គាំតមានអីគាត់អត្តចរិកគាត់គាត់ស្លូតដែរហ្នឹង!!

ក៖ហ៊ឺៗ!!

ខ៖គាត់ឡើងត្នោតគាត់ធ្លាក់ពីលើដើមត្នោតអីបានគាត់ឈឺដល់គាត់ស្លាប់ទៅណាស់!!គាត់ខ្វិនគាត់ងាប់មួយកំណាត់ខ្លួនបានគាត់ស្លាប់ហ្នឹង។

ក៖ហ្ហ៊ូ!!

ខ៖ហើយបានគាត់ឈឺហ្នឹង។

ក៖ហើយប៉ុន្មានឆ្នាំបានគាត់ស្លាប់?

ខ៖រយៈពេល៣ឆ្នាំ។

ក៖៣ឆ្នាំបានស្លាប់ហោ?

ខ៖បាទ!!

ក៖ហ៊ឺអានិតគាត់ណាស់ពូ!!!

ខ៖ គាត់នៅតែលើកន្ទេលលើគ្រែហ្នឹង។

ក៖ហ៊ឺៗ!!

ខ៖គាត់ខ្វិន។

ក៖ចាំ!!

ខ៖ហើយម្ដាយហ្នឹងចេះតែមើលថែទាំ កូនចៅអីអញ្ចឹងទៅណាស់!!

ក៖ចាំ!!

ខ៖ចេះថែទាំគាត់អីទៅ!!

ក៖ថៃទាំគាត់រហូតទាល់តែគាត់អស់ជីវិតអ៊ិចឹងទៅពូណោះ?

ខ៖បាទ!

ក៖អ៊ីចឹងដើមហេតុមកពីធ្លាក់លើដើមត្នោត ហើយគាត់ធ្លាក់៥ដងហ្ន៎និយាយរួម។

ក៖ ចំ !!ពូត្នោតមិនមែនទាបទេណាស់!!

ខ៖គាត់ធ្លាក់តាំងពីជំនាន់អាពតមកហើយមកយើងបែកអាពតហើយមកហ្នឹងធ្លាក់មួយសារទៀតគ្រាន់តែធ្លាក់។

ក៖ហ៊ឺចប់បណ្ដោយ!!

ខ៖បាទ!!

ក៖ដើមត្នោតកំពស់ៗម៉ាន កំពស់ដើមដូងនេះអត់នេះ?

ខ៖ ទេខ្ពស់ជាងហ្នឹង !!

ក៖ចំ!!

ខ៖ និយាយរួមពាក់កណ្ដាលអង់តែននេះអីវ៉ាន់ហ្នឹង!!

ក៖ចំពូខ្ពស់ខ្លាំងណាស់!!ខ៖បាទ!!ក៖តែពេលធ្លាក់ភ្លាមមកអត់ស្លាប់ភ្លាមទេ?

ខ៖ អត់ទេ។

ក៖តែហើគ្រាន់តែមានបាក់ដៃបាក់ជើងអីគេទេ?

ខ៖អត់ អត់ទេ។

ក៖សាហាវម្ល៉េះ ធម្មតាមនុស្សតែធ្លាក់ពីខ្ពស់គឺបាក់ដៃបាក់ជើងហើយ។

ខ៖អត់អីទេ គ្រាន់តែយើងយកគាត់មកឆ្អើរគាត់ឆ្អើរអីអញ្ចឹងទៅណាស់!!
ឆ្អើរភ្លើងឆ្អើរពន្លៃឆ្អើរអីអញ្ចឹងទៅ។

ក៖ហ្អ៎!!

ខ៖ កាលពេលយើងជំនាន់ហ្នឹង ឆ្អើរពន្លៃដាក់អីដាក់អីចាក់ថ្នាំ
!!ហាតែពន្លៃហើយហ្នឹងឆ្អើរភ្លើងហ្នឹងទេ!!

ក៖ហ៊ីៗ!!

ខ៖ឆ្អើរគាត់ទៅ រឹតពន្លៃរឹតអីជាមួយស្រាសរហ្នឹងទៅ!!

ក៖ចា៎!!

ខ៖បាទ!!

ក៖ហ៊ឺអានិតគាត់ណាស់ពូ!!

ខ៖បាទ!!

ក៖បើសិនជាធម្មតាបើធ្លាក់មកអ្នកខ្លះបាក់ករបាកអីស្លាប់បាត់ហើយ។

ខ៖អត់អីសំណាងគាត់ដែរដូចថាជីវិតគាត់ថ្លៃដែរ!!

ក៖ហ្នឹងហើយ ថ្លៃនេះមិនមែនថ្លៃធម្មតាទេ ថ្លៃខ្លាំងម៉ងហា៎!!

ខ៖ ៤ ៥ដងហើយ!!

កៈ ហើយមានដែលសួរគាត់ទេថាពេលធ្លាក់មកដោយសារវិលមុខឬក៏អីគេ?

ខៈ ដាច់នេះយើងដាច់ខ្សែ ចង!!

កៈអុះអាពអោងនោះហ្នឹងហែ?

ខៈ ពេលចងពអោងដាច់ខ្សែហា៎!!កៈហ្នូ!ខៈដាច់ខ្សែវាវត្តមក!!

កៈហ៊ឺៗ!!

ខៈហើយជួនកាលពេលយើងឡើងដល់លើអញ្ចឹងអាយើងបោះអាឈ្នួរ
បាក់អាឈ្នួរហ្នឹងធ្លាក់មកអញ្ចឹងទៅ!!

កៈ អូយ!!

ខៈបាទ!!

កៈតែនិយាយទៅអារកស៊ីឡើងត្នោតហ្នឹងវាប្រថុយជីវិតច្រើនណាស់ពូណេះ?

ខៈបាទ!!

កៈតែអត់ប្រយត្ន័ហ្នឹងទៅម៉ង!!

ខៈបាទ!!

កៈហើយអាពអោងហ្នឹងចងទៅប្រសិនជាខ្សែអត់មាំអីវ៉ាន់ហ្នឹង ដាច់ធ្លាក់មក។

ខៈ ដាច់ធ្លាក់!!

កៈហើយដើមត្នោតអូយ!!ហើយពូពេលគាត់ឡើងត្នោតហ្នឹងគាត់គ្រាន់តែឡើងហ្នឹងធ្វើតែស្ករឬក៏គាត់យកទឹកត្នោតហ្នឹងគ្រាន់តែយកទៅលក់។

ខៈ យកធ្វើស្ករ។

កៈ អ៊ីចឹងក្រុមគ្រួសារពូពេលមុនអ្នកធ្វើស្ករដែរហេ?

ខៈបាទ!!

កៈពូចេះរបៀបធ្វើស្ករហ្នឹងទេ?

ខៈចឹមិនចេះ!!!ញ៉ុមអត់ហ៊ានឡើងព្រោះឃើញឪធ្លាក់អ៊ីចឹងញ៉ូមអត់ហ៊ានឡើង។

កៈអត់ហ៊ានពូហេ?

ខៈបាទអត់ហ៊ាន!!ញ៉ុមបើឡើង ឡើងកាលីងញ៉ុមញ៉ុមអាចឡើងកើត។

កៈចាំ!!

ខៈបើអោយឡើងពអោងញ៉ូមអត់ទេ!!

កៈចាំខ្លាចពូណោះ?

ខៈ
បាទ!!ព្រោះញ៉ុមអត់ទុកចិត្តអារឿងពអោងខ្លាចបាក់!!បើយើងឡើងកាលីងហ្នឹងញ៉ុមអាចឡើងកើត!!

កៈអាឡើងទទេអ៊ីចឹងហេ?

ខៈ បាទ!!ឡើងកើត!!

កៈ ចំ!!តែដល់ពេលឡើងពអោង?

ខៈ អត់ហ៊ានឡើង។

កៈខ្លាចដាច់ខ្សែមក ?

ខៈ ហ្នឹងហើយខ្លាចដាច់ខ្សែ ខ្លាចបាក់កាំធ្លាក់មក។

កៈ ពូដូចនេះហាំ របៀបធ្វើស្ករត្នោតគេធ្វើម៉េចទៅពូអាចប្រាប់តិចមើល?

ខៈ ស្ករត្នោតយើងដាក់មកពីលើចុងអញ្ចឹងមកហើយយកមករំងាស់
ដាក់រំងាស់ហើយទៅដូចថាអាចថាវារឹងហើយ យើងយកមករិតទៅ។

កៈចាំ!!

ខ៖ រឹតវាអោយថាវាគោកអោយថាវាសរអញ្ចឹងយើងចាក់ទុកទៅ។

ក៖ និយាយអត់មានលាយអីទៀតណាហី?

ខ៖ អត់មានលាយអីទេ។

ក៖ គេអត់មានដាក់មេដាក់អីណាពូហី?

ខ៖ អត់មានទេ ប៉ុន្តែឥឡូវមានគេច្រើនលាយខ្លះ។

ក៖គេលាយអីគេវិញពូ?

ខ៖ គេលាយជាមួយម្សៅ ។

ក៖ហ្នឹងហើយ។

ខ៖ ហូបទៅមើលទៅរាងយើងដុំៗអាស្កររាងដុំម្សៅៗហ្នឹង
ហ្នឹងគេលាយម្សៅហើយ!!ក៖ហ្ហ៎!!ខ៖មើលយើងស្ករ ស្ករយើងនៅនឹងផ្សារព្រែកហូរយើងហ្នឹង។

ក៖ចាំ!!

ខ៖ មើលទៅអោយតែមើលរាងបែកពពុះហើយរាងដុំៗវាលាយម្សៅហើយ។

ក៖ហ៊ីចេះតែរកនឹកចេញម៉ងណោះ?

ខ៖ គេលាយម្សៅអោយធ្ងន់!!

ក៖ ចាំហ្នឹងហើយ បើសិនជាអត់!! វាហាត់មែនហ្នឹងហាំ!!

ខ៖បាទ!!ហាត់។

ក៖ តែគ្រាន់តែវាអត់បានសុទ្ធ។ហ៊ីចេះតែរកគំនិតឃើញហើយណាស់!!

ខ៖ គេលាយម្សៅអោយបានធ្ងន់ហ្នឹងនិយាយរួម !!បាទ!!

ក៖ចាំ ហ្នឹងហើយ
ពូចាំអីគេទៀតពីឪពុកដែលគាត់ធ្វើការងារអីវ៉ាន់ផ្សេងទៀតក្រៅពីឡើងត្នោតទេ?

ខ៖ គាត់វ៉ៃដែកវ៉ៃអីគាត់!!

ក៖ វ៉ៃដែកម៉េចពូ?

ខ៖ វ៉ៃដែកធ្វើកាំបិតធ្វើអីធ្វើពូថៅ ធ្វើជ្រុងពូថៅធ្វើជ្រុងអី។

ក៖ហ្ហ៎អ៊ីចឹងអ្នកធ្វើពូថៅធ្វើកាំបិតពូហោ?

ខ៖ បាទ!!

ក៖ហើយពូមានរៀនជំនាញហ្នឹងតពីគាត់ទេ?

ខ៖ អត់។

ក៖ អត់ព្រមរៀនមួយហ្នឹងបានចំនេញមួយហើយ!!បានមុខរបរមួយហើយពូណាស់!!

ខ៖អត់អត់រៀន។

ក៖ ហើយពេលគាត់ធ្វើមួយហ្នឹងគាត់យកទៅលក់អោយគេឬក៏ម៉េចវិញពូ?

ខ៖ គេយកមកជ្រុងនៅផ្ទះអញ្ចឹង!!

ក៖ ហ្ហ៎អាសិតអីវ៉ាន់ហ្នឹងអាមានដំប៉ុកប៉ាក់ៗហ្នឹងមែនពូហោ?

ខ៖បាទ!!

ក៖មានដុតភ្លើងដុតអីហ្នឹងហោ?

ខ៖ ដុតហ្នឹង ដុតភ្លើងហ្នឹង!!

ក៖ហ្ហ៎!!

ខ៖ដុតអោយក្រហមហើយយើងយកមកវ៉ៃអញ្ចឹងទៅ!!

ក៖ គេហៅជាងស្មូន ហ្នឹងហើយគេហៅជាងស្មូន ហោមិនមែនទេហោ??

ខ៖មិនមែនទេ។

ក៖មិនមែនទេ។

ខ៖អាហ្នឹងគេវ៉ៃដែក។

ក៖ ជាងដែកហ្នឹង។

ខ៖បាទជាងដែក។

ក៖ ច្រឡំជាងស្មូន ជាងស្មូនហ្នឹងជាងឆ្នាំងអីវ៉ាន់ទេ!!ពូមានចាំអីគេទៀតពីឪពុកទេ?

ខ៖ អត់។

ក៖អត់ទេហេ!!ភាគច្រើនអនុស្សាវរីយ៍គាត់នាំពូទៅដើរលេងណាខ្លះ?

ខ៖ ហ៊ីគាត់មិនសូវនាំញ៉ុមដើរផងព្រោះអីឃើញគាត់ឡើងត្នោតរហូត!!

ក៖ ម៉ាជីវិតគាត់គឺ២មុខហ្នឹងម៉ងពូហេ?

ខ៖ បាទ!!

ក៖តាំងពីពូដឹងក្ដីមកឃើញគាត់ធ្វើតែអីចឹងរហូតមែន?

ខ៖ បាទ!!

ក៖
អីចឹងពូសំរាប់ជីដូនជីតាវិញសំរាប់ខាងម្ដាយសិន!!យាយរបស់ពូខាងម្ដាយគាត់ឈ្មោះអីគេវិញខាងម្ដាយ?

ខ៖ ឈ្មោះយាយជុំ។

ក៖ ឥឡូវគាត់ស្លាប់ដែរហើយហេ?

ខ៖ ស្លាប់យូរហើយ។

ក៖ ហើយពូកើតទាន់គាត់ដែរតើហេ?

ខ៖ ទាន់។

ក៖ ហើយពូយាយម៉េចដែរលេងជាមួយគាត់ ធ្លាប់លេងជាមួយគាត់អីខ្លះទេ?

ខ៖ លេង ធ្លាប់លេងសើចជាមួយគាត់ ប្រលែង លេង បិចថ្ពាល់គាត់ប្រលែងលេងអីអឺចឹងទៅ!!

ក៖ ចឹបានដល់ថ្នាក់បិចថ្ពាល់ហើយ?

ខ៖ ចុះយើងស្រលាញ់គាត់ គាត់ធ្វើនំអាកោរ។

ក៖ហ្ហ៎!!

ខ៖ គាត់ធ្វើនំអាកោរពេលនេះធ្វើអោយចៅហូបអឺចឹងទៅណាស់!!

ក៖ចាំ!!

ខ៖គាត់លក់ខ្លះអោយចៅហូបខ្លះអឺចឹងទៅ។

ក៖ អឺចឹងយាយអ្នកធ្វើនំអាកោរលក់?

ខ៖បាទ។

ក៖ពូចេះធ្វើនំអាកោរហ្នឹងទេ?

ខ៖ ចឹចេះ។

ក៖ ធ្វើម៉េចទៅពូនិយាយបន្តិចមើល?ញ៉ុមចង់ដឹង។

ខ៖ កិនម្សៅទៅហើយយើងដាក់មេអោយឡើងទៅ ។ក៖ហ្ហ៎!!ខ៖ហើយយើងចាក់ទៅ ។

ក៖ ហើយអឺចឹងអាហ្នឹងលាយមេទៀត?

ខ៖ បាទ!!លាយមេ យើងយកមេត្នោតជូរដាក់។

ក៖ ទឹកត្នោតជូរ ហាំអឺចឹងពូពេលគេធ្វើទឹកត្នោតជូរគេសុទ្ធតែដាក់មេដាក់អីទេអឺចឹង?

ខ៖ អាខ្លះយក អាខ្លះគូរមេគូរទឹកយើងហ្នឹង ។

ក៖ហ៊ឺ!!

ខ៖គេដាក់មេ អាមេដំបែរហ្នឹងយកមកកូរទឹកហើយដាក់លាយទឹកត្នោតតិចៗអីចឹង !!

ក៖ហ៊ីធឹកហ្ន៎!!

ខ៖ តាមមើលឃើញ។

ក៖ នៅណាវិញពូគេធ្វើអញ្ចឹង?

ខ៖ នៅ និយាយរួមនៅ នៅម្តុំយើងលក់ហ្នឹង។

ក៖ ហ៊ីគ្មានបានទឹកត្នោតអីណាសុទ្ធណាអីចឹង?

ខ៖ ហ៊ីគ្មានទេ
គ្មានបានទឹកត្នោតណាបានលក់អោយឯងខូបប្រាំងខូបវស្សាទេ!!គេលាយអាអីចឹងតើ!!

ក៖ ចា៎!!អូយ ឥឡូវអីក៏មានដែរ ម៉ូតអីក៏មានដែរ ។

ខ៖ហើយមើលស្រា អាស្រាគេកូរហ្នឹង។

ក៖ចា៎!!

ខ៖ ស្រាកូរ ហើយឥឡូវត្នោតជូរមានកូរអីចឹងដែរកូរជាមួយទឹក
ហើយដាក់ទៅមិនដូចត្នោតជូរហើយយើងដាក់លាយត្នោតជូរអោយើងទឹកត្នោតហ្នឹងខ្លះទៅ
ដាក់លាយទឹកត្នោតបានតើ!!

ក៖ចា៎!!

ខ៖ហើយហូបទៅ រាគអាចមន៍ខ្លះអីខ្លះ។

ក៖ តែញ៉ុមឆ្ងល់ដោយសារអាមេហ្នឹងបានស្រវឹងហ្នឹងមែនពូ?

ខ៖បាទ!!

ក៖ហ៊ី!!

ខ៖ ចុះមេដូចតែមេស្រាដែរហ្នឹង។

កះចាំ!!

ខះ ដូចប៉ុណ្ណឹងៗគ្រាប់វា។

កះចាំ!!គេធ្វើមកពីណាវិញពូណោះ?

ខះ គេទិញមកពីយួន។

កះ មកពីយួនទៀត?

ខះ បាទ!!

កះស្អីទេអាយួនហ្នឹងវាចេះធ្វើមេគ្រប់សព្វអីចឹង!!

ខះបាទ!!

កះវាចេះទាំងអស់ម៉ងហា!! មើលពូគេធ្វើម៉េចវិញទៅទៀតអាកោរហ្នឹងញ៉ុមភ្លេចបាត់ហើយ!!

ខះ អាកោរយើងកិនម្សៅយើងទៅ។

កះហើយលាយជាមួយមេ?

ខះបាទហើយយើងដាក់លាយជាមួយមេត្នោតជូរយើងហ្នឹងទៅ។

កះ ហើយស្ករសរហ្នឹងទៅពូហោ?

ខះ បាទយើងដាក់ស្ករសរក៏បានយើងដាក់ស្ករត្នោតយើងក៏បាន។

កះហើយអីគេទៀតទេ?

ខះ ដាក់តែប៉ុណ្ណឹង។

កះហើយខ្ទិះដូចយើងអត់ដាក់ណាហី?

ខះ យើងដាក់ យើងដាក់ដូងដាក់ពីក្រោយទេ។

កះហ្អ៎!!

ខ៖ កោសដូងដាក់ទៅ។គេដាក់កូនចានប៉ុណ្ណេះហ្នឹងកូនចានអាកោរ។

ក៖ ចាំ!!ហើយដាក់ចំហុយវាទៅ?

ខ៖ បាទហើយដាក់ចំហុយវា
ហើយដាក់ធូបមួយដើមហើយកំនត់វាថាឆ្អិនប្រវែងម៉ានប្រវែងម៉ានអីចឹងទៅ!!យើងដឹង។

ក៖ អញ្ចឹងទៀត?

ខ៖ បាទ!!

ក៖ អើរនិយាយ ស្អីគេអុជធូបមួយដើមពូហោ?

ខ៖ បាទ!!

ក៖ ចំឡែយម្លេះ!!

ខ៖ ក្នុងម៉ានេះហ្នឹង ក្នុងម៉ានេះហ្នឹងអស់ធូបអស់ពាក់កណ្ដាលធូប។

ក៖ គេកំនត់ម៉ងពូហោ?

ខ៖ បាទ!!

ក៖ តែត្រូវតែភ្លើងអោយដល់?

ខ៖ បាទ!!ដុតភ្លើង។

ក៖ ភ្លើងអោយខ្លាំងអីចឹងទៅ?

ខ៖ បាទ!!

ក៖
ចាំមើលថ្ងៃណាមួយធ្វើអាកោរហូបម្ដងខ្លួនឯង។ញ៉ុមទិញតែគេហូបតែអារឿងធ្វើខ្លួនឯងមិនដែលធ្វើម៉ង ម៉ាជីវិតមិនដែលឃើញគេធ្វើសោះ។

ខ៖ គេធ្វើអាកោរលក់អាកោរអស់ងងុយណាស់។

កៈម៉េចអ៊ីចឹងវិញ?

ខៈ ភ្ញាក់ចំហុយ ឡើងថ្មើរម៉ានយើងចំហុយថ្មើរហ្នឹង!!

(មិត្តភក្តិ)ៈ តែម្សៅឡើងយើងចាប់ផ្ដើមចំហុយ។

ខៈ តែយើងឡើងយើងអត់នេះហ្នឹង ឡើងហួសវាខូចទៀត។

កៈ ឡើងម្សៅហ្នឹង?

ខៈបាទ!!

កៈ ម៉េចវិញពូឡើងម្សៅហ្នឹង?

ខៈ ពេលឡើងហ្នឹង
ឡើងយើងផុចៗៗដូចយើងបាយផ្អូមអ៊ីចឹង!!ដូចបាយផ្អូមអិចឹងយើងឡើងផុចៗៗអញ្ចឹងទៅ!!

កៈ ត្រូវមើលរហូតហោ?

ខៈហោយើងឧស្សាហ៍ភ្ញាក់មើលទៅ!!

(មិត្តភក្តិ)ៈ ដឹងពេល។

ខៈ បាទហើយពេលដែលវាថាវាឡើងលែងនេះហ្នឹង ក្រាបវិញហើយ
អាហ្នឹងលែងឡើងហើយ។

កៈ ចាំ!!

ខៈតែឡើងហួសទៅហាំ!!

កៈចាំ!!

ខៈពេលហ្នឹងក្រាបម្សៅវិញ!!

កៈ តែយើងពេលហ្នឹង យើងមានលាយមេនៅក្នុងហ្នឹងអោយហើយអត់?

ខៈ លាយមេ អាមេត្នោតជូរហ្នឹង។

កៈ លាយពេលល្ងាចអោយហើយមែនពូពេលហ្នឹង?

ខៈ បាទ!!

កៈហើយយើងទុកអញ្ចឹងទៅ?

ខៈ ហ្នឹងយើងទុកទៅ ទុករហូតទៅទុកតិចៗរហូតលាយទៅ។

កៈ
ហើយដល់អញ្ចឹងយើងដឹងថាដល់ម៉ោងដល់ពេលថាវាឡើងយកដាក់ចានដាក់អីចំហុយទៅ?

ខៈបាទ!!

កៈហ្ហ៎អញ្ចឹងម្យ៉ាងដែរ!!ហ្នឹងហើយ ហើយយាយកើតឆ្នាំអីគេដែរពូចាំទេ?

ខៈអត់ អត់ចាំ។

កៈហើយតែពេលគាត់ស្លាប់អាយុប៉ុន្មានពូចាំទេ?

ខៈអត់ចាំ។

កៈ អ៊ីចឹងយាយពូអត់ចាំទាំងអស់ម៉ងហេ?

ខៈបាទ!!

កៈហើយអ្នកស្រុកមកពីណាវិញយាយ?

ខៈស្រុកនៅហ្នឹងដែរ។

កៈ សុទ្ធតែអ្នកនៅហ្នឹងទាំងអស់?

ខៈបាទ!!

កៈ ទាំងឪទាំងម៉ែ ទាំងយាយ?

ខៈបាទ!!

កៈឥឡូវតាវិញចំមើលអ្នកស្រុកណាដែរ?

ខៈ តាអ្នកស្រុកហ្នឹងដែរ!!

កៈតាឈ្មោះអីគេវិញខាងម្ដាយ?

ខៈនេះណៃ គាត់ឈ្មោះភោគ។

កៈតាភោគ?

ខៈ បាទ!!

កៈ អីគេភោគវិញពូ? ត្រកូល?

ខៈ អត់ស្គាល់។

កៈស្គាល់ឈ្មោះតែតាអ៊ីចឹងទៅ?

ខៈ បាទ!!។

កៈ អ្នកស្រុកមកពីហ្នឹងដែរ?

ខៈ អ្នកស្រុកហ្នឹងដែរ។

កៈចាំ!!

ខៈបាទ!!

កៈ ពូកើតទាន់តាទេ?

ខៈទាន់។

កៈទាន់នៅពេលគាត់រស់ដែរហេ?

ខៈបាទ!!

កៈ គាត់ស្លាប់ប៉ុន្មានឆ្នាំហើយពូតា?

ខ៖ ស្លាប់និយាយរួមយូរដែរហ្នឹង ១៣ ១៤ឆ្នាំហើយ!

ក៖ចាំ!!

ខ៖បាទ!!

ក៖ អញ្ចឹងគាត់ស្លាប់មុនឪពុករបស់ពូឬក៏ក្រោយឪពុកពូ?

ខ៖ស្លាប់មុន។

ក៖ មុនប៉ុន្មានឆ្នាំទៅ?

ខ៖ ស្លាប់មុន៣ ៤ឆ្នាំមុន។

ក៖អីចឹង២០០៥អីវ៉ាន់ហ្នឹងពូហោ?

ខ៖បាទ!!

ក៖២០០៤ ២០០៥អីចឹងទៅហោ?

ខ៖ យាយហើយនឹងតាស្លាប់មុន។

ក៖ ហ៊ើៗ!!ពេលតាស្លាប់វិញអាយុប៉ុន្មានពូចាំទេ?

ខ៖បាទ!!

ក៖តាស្លាប់អាយុប៉ុន្មាន?

ខ៖ អត់ស្គាល់មិនដឹងអាយុប៉ុន្មាន?

ក៖ចុះយាយអត់ដឹងដែរហោ?

ខ៖ យាយអត់ដឹងដែរព្រោះញ៉ុមនៅក្មេងដែរហាំ!!

ក៖ចាំ!ហើយពូចាំអីគេខ្លះពីតា?

ខ៖ចាំតាគាត់ឡើងត្នោតដែរ
ចាំពេលគាត់ឡើងត្នោតដាំជំឡូងអីពេលពេលហ្នឹង!!ជំឡូងជ្វាយើង!!

ក៖ហ្អចាំ!!ពូដែលទៅជួយដាំជំនាំគាត់អីហ្នឹងអត់?

ខ៖ដែល។

ក៖ដែលដែរហេ?

ខ៖ ដាំជំឡូងជ្វាអំពៅអីអឹចឹងទៅគាត់ដាំ។

ក៖ ដំាជំឡូងជ្វាដឹងតែយកមើមហើយប៉ុន្តែល្ពៅដាំយកផ្លែយកត្រួយលោកពូ?

ខ៖ ដាំយកផ្លែយកត្រួយអីយកលក់អញ្ចឹងទៅ!!ផ្កាអីអឹចឹងទៅ!!

ក៖ គ្រប់សព្វទាំងអស់អញ្ចឹងពុហេ?

ខ៖បាទ!!

ក៖ពេលជំនាន់ណាពូពេលគាត់ធ្វើហ្នឹង?បែកអាពតហើយឬក៏ម៉េចពូ?

ខ៖ បែកអាពត។

ក៖ ហ្អអឹចឹងពួកគាត់សុទ្ធតែបានរួចផុតពីសង្គ្រាមទាំងអស់ហ្នឹងអឹចឹង។

ខ៖បាទ!!

ក៖អញ្ចឹងល្អណាស់អឹចឹងហេងវិញ។

ខ៖បាទ!!

ក៖ ចាំអឹចឹងពូអនុស្សាវរីយ៍ដែលពូចាំអត់ភ្លេចជាមួយតាគេអីគេវិញទៅ
ចំនុចកន្លែងណាដែលពូស្រលាញ់តាជាងគេអឹចឹងហាំ!!

ខ៖ឡើងត្នោតហើយដាំជំឡូង ហើយនឹងទៅដាំជំឡូងជាមួយគាត់។

ក៖ចាំគាត់ចិត្តល្អទេតា?

ខ៖ គាត់ចិត្តល្អ។

ក៖ ដូច និយាយថាតា គាត់មានកូនប៉ុន្មាននាក់ពូ?ដឹងទេ?

ខ៖កូន៧នាក់។

ក៖៧នាក់ជាមួយនឹងយាយហ្នឹងហោ?

ខ៖បាទ!!

ក៖តែកូនគាត់អីសុទ្ធតែនៅរស់ដល់សព្វថ្ងៃ?

ខ៖ នៅតើ!!នៅរត់តែ២នាក់ទេ!!

ក៖ហ្ហ៎!!

ខ៖នៅម្ដាយញ៉ុមហ្នឹងហើយពូញ៉ុមនៅតែ២នាក់ហ្នឹងទេ។

ក៖ ចាំអញ្ចឹងពូគ្រាន់តែអនុស្សាវរីយ៍របស់ពូ ភាគច្រើនតែទៅធ្វើចំការជាមួយនឹងគាត់ទេ?

ខ៖បាទ!!

ក៖ចាំ ឥឡូវចូលដល់យាយខាងឪពុកវិញយាយខាងឪពុកឈ្មោះអីគេ?

ខ៖ យាយខាងឪពុកញ៉ុមអត់ចាំព្រោះគាត់ស្លាប់តាំងពីជំនាន់អាពតម៉ង អាពតធ្វើស៊ីអស់ហើយ!

ក៖ សម្លាប់សាហាវ ពូដឹងថាគាត់ពួកវាយកទៅសម្លាប់ចោលមូលហេតុអីអត់?

ខ៖ អត់ដឹង អត់ដឹងថាសម្លាប់មូលហេតុអី
គ្រាន់តែយើងដឹងថាយកយើងទៅថាទៅទៅណោះទៅណោះអ៊ីចឹងទៅណាស់!!

ក៖ហ្ហ៎!!

ខ៖ទៅអញ្ចឹងទៅថាយកទៅណោះទេអត់អីទេ ហើយយកទៅបាត់រហូតទៅ ។

ក៖ចាំ!!

ខ៖បាទ!!

(មិត្តភក្តិ)៖ ហ្នឹងគេយកទៅដាំដំឡូងយកទៅដាំអីហ្នឹងសុទ្ធតែងាប់ហើយ។

ខ៖ យកទៅបាត់រហូតទៅ។

ក៖ចាំ!!

ខ៖អត់ឃើញមកវិញ។

ក៖បាត់ឈឹងម៉ងទៅពូហេ?

ខ៖ បាទ!!

ក៖ ហ្នឹងហើយអញ្ចឹងមានដែលឪពុកពូដែលប្រាប់ថាដែរអីអត់ យាយហីតាមិញ?

ខ៖តា!!

ក៖តាហ្នឹងហើយ!!

ខ៖ តាខាងឪពុក។

ក៖ហ្នឹងហើយម៉េចគាត់មានដែលនិយាយប្រាប់អីគេអីខ្លះអត់?

ខ៖អត់ញ៉ុមកើតអត់ទាន់គាត់។

ក៖តា!!និយាយថាឪពុកពូប្រាប់ពីតាហ៎ាគាត់ជាមនុស្សម៉េចដែរអញ្ចឹងហាពូណាស់!!

ខ៖ ចុះមានអីគ្រាន់តែប្រាប់ថាតាឈ្មោះតា សៀមយាយបាវអីអញ្ចឹងទៅ!!

ក៖ឈ្មោះតាសៀមអ៊ីចឹងហេ?

ខ៖បាទ!!តាញ៉ុមគាត់មកពីសៀមតើ!!

ក៖ហ្អ៎អ៊ីចឹងជនជាតិថៃទេអ៊ិចឹង?

ខ៖បាទ!!ហើយទៅស្រលាញ់ជាមួយយាយញ៉ុមឈ្មោះយាយ!!

កះហ្នឹអិចឹងពូកាត់ខ្សែថៃដែរអិចឹងទៅហេ?

ខះបាទ!!

កះតាសៀម យាយបាវ។

ខះបាទ!!

កះអត់មានបានចាំត្រកូលគាត់ទេពូហេ?

ខះ អត់។

កះ ចាំអញ្ចឹងស្រុកកំនើតរបស់តារបស់លោកពូមិនមែននៅហ្នឹងទេ។

ខះយាយញ៉ុមនៅស្រុកហ្នឹង ហើយដល់ពេលតាមកពីខាងសៀម។

កះ ប្រទេសថៃ។

ខះហើយដឹងកាលហ្នឹងស្របក់ហ្នឹងគាត់ត្រូវរ៉ូវគ្នាម៉េចទេ!!បានមកស្គាល់យាយហ្នឹង!!កះចាំ!!ខះស្គាល់គ្នាទៅ!!

កះចាំ!!អត់ដឹងប្រវត្តិស្នេហាគាត់ទេហេ?

ខះ អត់!!

កះអញ្ចឹងពូសំរាប់យាយ យាយឈ្មោះយាយបាវហេ?

ខះបាទ!!

កះពូកើតទាន់យាយបាវទេ?

ខះអត់ទាន់!!

កះ អញ្ចឹងខាងឪស្លាប់ចោលទាំង២នាក់?

ខះបាទខាងម្ដាយហ្នឹងទាន់។

ក៖ចាំ!!

ខ៖តែខាងឪពុកអត់ទាន់ទេយាយ។

ក៖ហើយឥឡូវឪពុកមានដែលនិយាយប្រាប់អីគេខ្លះអំពីម្ដាយអីទេ?

ខ៖ អត់។

ក៖ អត់ដែរ?

ខ៖បាទ!!

ក៖ថាអ្នករកស៊ីម៉េចដែរអីអត់ទេហោ?

ខ៖ អត់ទេ។

ក៖ដូចពីដើមយើងរកស៊ីអីអត់ប្រាប់ទេ?

ខ៖ ចុះពីដើមយើងរកស៊ីអី ពីដើមគិតតែរត់។

ក៖ហ្ន៎!!

ខ៖ជំនាន់អាពតបានអីរកស៊ី!!

ក៖ហ្នឹង!!ចុះអាមិនទាន់រត់នោះហ្ន៎??

ខ៖ មិនទាន់រត់ដឹងរកស៊ីអីញ៉ុមអត់ដឹងដែរ។

ក៖
អញ្ចឹងលោកពូសំរាប់លោកពូមានបងប្អូនណាដែរដែលធ្លាប់ទៅរស់នៅប្រទេសក្រៅអត់?ដឹងតែតាគាត់មួយជនជាតិថៃហើយតែ!!

ខ៖អត់អត់មាន។

ក៖ចុះបើបងប្អូនជីដូនមួយអីគាត់មានអ្នកណាគេធ្លាប់ទៅរស់នៅប្រទេសខាងក្រៅអីអត់?

ខ៖ អត់ទេ អត់។

កៈឬក៏ទៅធ្វើការនៅថៃអីអញ្ចឹងហាំ??

ខៈ អត់ អត់មានទេ។

កៈ អត់មានទាំងអស់ម៉ងអញ្ចឹងហោ?

ខៈបាទ!!

កៈចាំ!!ហើយចុះសំរាប់លោកពូ
លោកពូចេះអានហើយនឹងសរសេរភាសាខ្មែរបានច្បាស់ល្អអត់?

ខៈ អត់ចេះម៉ង!!

កៈ ពូអត់បានអានអីច្បាស់ទេ!!

ខៈអត់បានអានរៀនម៉ងញ៉ុមចេះតែឈឺបែកពីអាពតហើយមក!!

កៈចាំ!!អ៊ីចឹងពូអត់បាន!!

ខៈអត់បានរៀនទេ!!

កៈ ចាំ!!ពូសំរាប់ពេលវេលាមួយណាដែលនៅក្នុងជីវិតពូ
ពូគិតថាពេលវេលាមួយណាដែលពូគិតថាវាលំបាកបំផុតនៅក្នុងជីវិតហាំ?

ខៈ ជីវិតហ្នឹងលំបាកវេទនាណាស់។

កៈម៉េចដែរលំបាករឿងអីគេ?

ខៈ លំបាកញ៉ុមរឿងកូន។

កៈ ម៉េចវិញពូ?

ខៈលំបាកនិយាយរួមម៉ែគេមានប្តីទៀតចោលកូន។

កៈប្រពន្ធពូហ្នឹង?

ខៈ ប្រពន្ធមុន ញ៉ុមមានប្រពន្ធ២។

កៈហ្អ៎!!ពូធ្វើបាបគាត់ទេហើបានគាត់រត់ចោលពូខូច?

ខៈមិនមែនទេ គេទៅចោលកូនហើយកូននៅតែជាមួយបងៗវាហ្នឹង!!កូនញ៉ុមមាន២នាក់។

កៈចា៎!!

ខៈតែកូនបងនៅជាមួយបងហើយកូនមួយទៀតនៅជាមួយអ៊ំ
ហើយម្ដាយរត់ទៅចោលបាត់ហើយញ៉ុមសព្វថ្ងៃចេះតែបារម្ភពីកូន។

កៈហ្អ៎!!

ខៈបាទ!!

កៈអញ្ចឹងពិបាកមួយទៀតគឺរឿងកូន?

ខៈបាទ!!

កៈអត់មានអ្នកថែទាំអីចឹងទៅណោះ?

ខៈបាទ!!

កៈអូខេអ៊ីចឹងមានអីដែលពិបាកទៀតទេនៅក្នុងជីវិត?

ខៈអត់មានពិបាកតែប៉ុណ្ណឹង។

កៈហ្នឹងអូខេ
អញ្ចឹងអរគុណច្រើនលោកពូសំរាប់ការសំភាសន៍ដែលពូបានប្រាប់នូវអំពីប្រវត្តិក្រុមគ្រួសារនឹង
ជីដូនជីតា។

ខៈបាទ!!

កៈអរគុណណាស់ពូ។

ខៈបាទ។